**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
Kingdom of Cambodia
Nation Religion King

**ក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
Ministry of Industry & Handicraft
លេខ : ៤៨០ ឧស.ឧ.ល.លស

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១៦

**ជម្រាបមក**
**ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយិកា អគ្គាធិការ**
**ប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ**
**គ្រប់ប្រធាននាយកដ្ឋានទាំងអស់ក្រោមឱវាទក្រសួង**

**<u>កម្មវត្ថុ</u>** ៖សំណើសុំផ្តល់ឈ្មោះមន្ត្រីរាជការដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរនៅតាមអង្គភាពក្រោមឱវាទក្រសួង។
**<u>យោង</u>** ៖យោងតាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តមទេសរដ្ឋមន្ត្រី នៅថ្ងៃទី ០៦ ខែមីនា ឆ្នាំ ២០១៦។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបមក **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានអង្គភាពក្រោមឱវាទក្រសួងជ្រាបថា៖ក្នុងគោលបំណងជួយសម្រួល និងផ្តល់កិច្ចអន្តរាគមន៍ក្នុងការដោះស្រាយបញ្ហាផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនដល់មន្ត្រីរាជការ ដែលកំពុងបម្រើការងារនៅរដ្ឋបាលកណ្តាល សំដៅផ្តល់លទ្ធភាពដល់មន្ត្រីរាជការអាចបំពេញកាតព្វកិច្ចទៅចូលរួមការបោះឆ្នោតនាពេលខាងមុខ ស្របតាមលក្ខខណ្ឌច្បាប់ ក្រសួងសំណូមពរដល់គ្រប់អង្គភាពក្រោមឱវាទ សូមបញ្ជូនឈ្មោះមន្ត្រីរាជការ(រាប់ទាំងមន្ត្រីជាប់កិច្ចសន្យា) ដែលមិនទាន់បានបំពេញបែបបទស្នើសុំអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ជូនមកនាយកដ្ឋានបុគ្គលិក ឱ្យបាន**មុនថ្ងៃទី ១៥ ខែមីនា ឆ្នាំ២០១៦** ដើម្បីធ្វើការបូកសរុប និងស្នើសុំអន្តរាគមន៍ទៅក្រសួងមហាផ្ទៃ ឬ ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ពិនិត្យដោះស្រាយឱ្យបានឆាប់រហ័ស តាមនីតិវិធីជាធរមាន។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាប្រធានអង្គភាពក្រោមឱវាទក្រសួង ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព។

**ជ. រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**រដ្ឋលេខាធិការ**

**គីម ធូច**

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263